# ការសម្ភាសរបស់លោកយាយ ប៉ែន យាន

*កៈ អ្នកសម្ភាស សេង ដាវីដា ខៈ អ្នកត្រូវគេសម្ភាស ប៉ែនយាន*

កៈ អញ្ចឹងដើម្បីចាប់ផ្ដើមសម្ភាសនេះ ខ្ញុំត្រូវប្រាប់ទីតាំងគេជាមុនសិន។ អញ្ចឹងអើឥឡូវយើងនៅភូមិអាចារ្យលាក់ ហើយសង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ហើយនៅថ្ងៃទី២៨ ខែ២ ឆ្នាំ២០១៩ ហើយជាដំបូងនៃការសម្ភាសរបស់យើង ចឹងយើងសុំអនុញ្ញាតិដើម្បីស្គាល់ឈ្មោះលោកយាយ យាយ?

ខៈឱ្យដឹងហាក់?

កៈ យាយឈ្មោះពេញ យាយ ឈ្មោះពេញឈ្មោះអីគេដែរលយាយ?

ខៈ យាយឈ្មោះប៉ែន យ៉ាន កូនអាក្រៅគេហៅយាយរឹទ្ធ។

កៈ អូ!

ខៈ អឺ!

កៈ មានឈ្មោះអីក្រៅពីឈ្មោះ២ហ្នឹងទេយាយ?

ខៈ អត់មានទេចៅ មានតាប៉ុណ្ណោះឯង

ឪកៈ យាយមានអាយុប៉ុន្មានហើយឆ្នាំហ្នឹងយាយ?

ខៈ ៧៥នេះហើយចៅ អឺ ៧៥ឆ្នាំថ្មី ប៉ុនអាយុចូលដល់ទៅ ប្រាសាកឯនោះចៅ បានចូល៧៥ហ្មំ យើងនៅក្នុងខែ២ នៅត្រង់៧៤នៅឡើយទេ

កៈ ចាស! ចុះយាយចាំ យាយកើតក្នុងឆ្នាំណាអត់យាយ ?

ខៈ អត់ដឹងផង ប៉ុនដឹងតាឆ្នាំកំណើតនិង ឆ្នាំរក។

កៈ ឆ្នាំរក!

ខៈ ប៉ុនអត់ដឹងថាឆ្នាំអី។

កៈ ចឹងយាយនៅក្នុងឆ្នាំ អាយុ៧៤ ចឹងយើងដកមកវិញនៅឆ្នាំ១៩៤៥ ឆ្នាំដែលយាយកើតហ្នឹង។

ខៈ ឆ្នាំដែលយាយកើតហ្មំ

កៈ ឆ្នាំខ្មែរយាយឆ្នាំរក។

ខ៖ អឺ!

ក៖ ហ្ន៎យាយ។

ខ៖ ឆ្នាំវកថៅ។

ក៖ ចាស! ចុះអើយាយកើតនៅ នៅទីណាដែរយាយ?

ខ៖ យាយកើតនៅភូមិទឹកវិល។

ក៖ ឃុំអីគេដែរយាយ?

ខ៖ ឃុំក្លែង ស្រុកសណ្ដាន់។

ក៖ ខេត្តកំពង់ធំហ្ន៎យាយ?

ខ៖ ខេត្តកំពង់ធំ។

ក៖ យាយមានបងប្អូនម៉ាននាក់ដែរយាយ?

ខ៖ បងប្អូន៤នាក់ ស្រី៣ប្រុស១។

ក៖ យាយ!

ខ៖ ប្រុសតែតាយើងហ្នឹងឯងថៅ។

ក៖ យាយកូនទីប៉ុន្មានដែរយាយ?

ខ៖ កូនយាយហ្ន៎។

ក៖ ចាស!

ខ៖ មើល តាសាន្ត យាយរីទ្ធ យាយកុក យាយជា។

ក៖ យាយកូនទី៣។

គ៖ អឺ ទី២!

ខ៖ អូ ទី២!

ក៖ ចឹង!

ខ៖ យាយកុកទី៣ យាយជាទី៤ ចុះឯងបាវថៅអឺ។

កៈ តាសាន្តទី១។

ខៈ តាសាន្តទី១ តាសាន្តបងយាយ។

កៈ បងប្អូនយាយ គាត់ធ្វើអីគេខ្លះដែលរយេ? តាសាន្ត។

ខៈ គ្មានធ្វើអីទេចៅ មានតាធ្វើស្រែចម្ការ។

កៈ ចុះតាសាន្តគាត់ធ្វើអីគេដែរយាយ?

ខៈ តាសាន្តប៉ុន្មានជំនាន់នោះដូចតា ធ្វើទាហាន តែមិនដឹងទាហានអី ប៉ុន្មានជំនាន់នោះចៅ។

កៈ តាម

ខៈ ទាហានគាត់ នៅទទួលខាងហិរញ្ញវត្ថុហ្នឹងឯង។

កៈ ហ្នឹងហើយ គាត់ដូចជាខាងហិរញ្ញវត្ថុនៅខាងសង្គមកិច្ច។

ខៈ អឺ!

កៈ តាសាន្ត។

ខៈ អឺ! សម្រាប់បើកលុយបើកកាក់។

គៈ អូ! កាតូចយាយថ្លង់ហើយថ្លង់ ឯងឺតក៏ឯងឺត។

ខៈ មានតាបងមួយហ្នឹងឯង។

គៈ ថ្លង់ក៏ថ្លង់អើយ។

ខៈ បានធ្វើការ បើប្អូនស្រីៗគ្មានបានអីទេ។

គៈ កុំតាចៅមកឈប់ញាចចេះហៅ។

ខៈ បានតាធ្វើស្រែចម្ការចឹងឯង។

កៈ អើនៅពីក្មេងយាយនៅជាមួយគាត់នែកនៅជាមួយ។

ខៈ នែក!

កៈ គាត់ទាំងអស់គ្នាតើហីយាយ?

ខៈ ពីក្មេងនៅតូចៗដែលមិនទាន់មានគ្រួសារ នៅជួបជុំបងប្អូនទាំងអស់គ្នា។

កៈ ចាស!

ខៈ ដល់មានគ្រួសាររៀងខ្លួនទៅ បងនៅតាមគ្រួសារ យាយនៅតាមគ្រួសារយាយ រស់នៅជាមួយយាយ។

កៈ ចាស!

ខៈ យាយទឹម!

កៈ យាយទឹម!

ខៈ យាយទឹមប្រហែលនៅ៨៧។

កៈ សព្វ!

ខៈ យាយទឹក៨៧។

កៈ សព្វថ្ងៃអើ។

គៈ ចាំមិនអស់។

កៈ គាត់នៅណាខ្លះដែរយាយ?

ខៈ ថាម៉េចចៅ?

កៈ សព្វថ្ងៃពួកគាត់នៅណាខ្លះដែរ?

ខៈ និយាយពីអីនិយាយពីយកម៉ែហាក់?

កៈ បងប្អូនៗយាយ។

ខៈ បងប្អូនគាត់នៅភូមិទឹកវិលទាំងអស់ហ្នឹងឯងចៅអើ។

កៈ ហ្នឹង ស្លាប់តែតាសាន្តមួយហ្នំយាយ?

ខៈ អឺ ស្លាប់តែតាសាន្តទេ ស្លាប់អស់គ្នាឯង នៅក្រុមគ្រូប៉ុន្មាន នៅតាមេៗទេ។

គៈ មានតែតាហាងតើនៅកំពង់ធំ។

ខៈ នៅតាកូនៗ នៅតាកូនក្រោយៗហួសពីនេះនៅ។

គៈ នៅតែតាសាន្ត។

ខៈ ធ្វើស្រែចម្ការទាំងអស់។

ក៖ តែបងប្អូនយាយមានតែតាសាន្តតើហីស្លាប់?

ខ៖ អឺមានតែតាសាន្ត ប្រុសទីមួយ។

គ៖ ប្រុសមានតែមួយ។

ខ៖ ស្រី៣!

គ៖ ស្រី៣ចៅ នៅទាំង៣ឯងស្រី។

ក៖ ចាស!

គ៖ តាញិក ប្រពន្ធតាញិកហ្ក់  តាញិកហាងហ្ក់ ស្លាប់បាត់ហើយ។

ក៖ ចាស!

គ៖ ចៅ!

ខ៖ ដឹងហើយតើចៅ។

ក៖ យាយអើម្តាយរបស់យាយឈ្មោះអីគេដែរ?

ខ៖ ឈ្មោះយាយទឹម។

ក៖ យាយមានចាំត្រកូលគាត់អត់?

ខ៖ ហើយឪពុកគាត់ ចាំកូន នៅ នុច ទឹម។

ក៖ នុច ទឹម!

ខ៖ អឺ!

ក៖ ចុះអើឪពុករបស់យាយឈ្មោះអីគេ?

ខ៖ ឪពុកយាយឈ្មោះ តាប៉ាត។

ក៖ អីគេប៉ាត?

ខ៖ ត្រកូលគាត់ កែវ  ឈ្មោះកែវ។

ក៖ កែវ ប៉ាត!

ខ៖ កែវ ប៉ាត ប្រពន្ធគាត់ឈ្មោះ នុច ទឹម ត្រកូល។

គះ កាទូច កើតកំពង់ធំសោះ។

កះ ចាស!

ខះ មីអូន!

កះ ខ្ញុំនៅកំពង់ធំយាយ។

ខះ កើតនៅកំពង់ធំហ្នឹងឯង។

ឃះ កូនពីណា?

ខះ កូន!

គះ ខ្លាចកូនតាសាន្តហាង។

កះ ចៅ ចៅតាសាន្ត។

គះ អូ! ចៅតាសាន្ត។

ខះ ហ្នឹងឯង ចៅតាសាន្ត។

គះ កូនយាយញ៉ែប។

ខះ ចៅយាយញ៉ែប។

ឃះ អូ!

គះ កូនមីចិ។

ខះ អឺ!

ឃះ អូ! កូនមីចិឯង។

កះ ចាស!

ឃះ មីទី២មែន?

គះ មី៧!

កះ ទី៣!

ឃះ អូ!

គ៖ មីឡុងហើយវា។

ក៖ ខ្ញុំបន្ទាប់ពី៣។

ខ៖ ៣មួយអាប្រុស។

ក៖ ចុះយាយ ឪពុកម្ដាយយាយឥឡូវគាត់ចែកឋានអស់នៅយាយ?

ខ៖ ស្លាប់អស់ហើយ។

ក៖ គាត់ស្លាប់នៅអាយុប៉ុន្មានដែរយាយ?

ខ៖ យាយអាយុ៧៧។

ក៖ ៧៧ហ្នឹង?

ខ៖ ដល់តាហារ៨៥

ក៖ ចឹងលោកយាយ៧៨ លោកតា៨៥។

ខ៖ អឺ!

ក៖ អើលោកយាយចាំថាពួកគាត់កើតនៅឆ្នាំណាអត់? ឆ្នាំខ្មែរក៏បាន។

ខ៖ គាត់នែកប្រពន្ធគាត់ឆ្នាំរកា ប្ដីគាត់ឆ្នាំម្សាញ់ តែមិនដឹងប៉ុន្មានហើយ អូ! នែកដឹងប៉ុន្មានហើយ ដឹងតាកើតនែកឆ្នាំរកាឆ្នាំម្សាញ់ហ្នឹង ដឹងនែកនៅក្នុងឆ្នាំទីប៉ុន្មាន។

ក៖ ចាស!

ខ៖ គាត់៨៥។

ក៖ ហ្នឹងហើយ។

ក៖ ប្រពន្ធគាត់៧៧ ប្ដីគាត់បង បងជាង១០ឆ្នាំ។

ក៖ យាយចុះអើរ យាយដឹងថា ឪពុកម្ដាយយាយគាត់អឺទីកន្លែងកំណើតរបស់ពួកគាត់នៅណាទេយាយ?

ខ៖ កើតនៅភូមិទឹកវិលនោះឯងថៅ។

ក៖ ទាំង២នាក់ហ្អ៎។

ខ៖ ទាំង២នាក់ហ្នឹងឯង។

កៈ ចុះ...

ខៈ ភូមិជាមួយឃុំជាមួយ។

កៈ លោកតាគាត់ធ្វើការអីគេដែរយាយ?

ខៈ អត់ធ្វើអីទេចៅ ធ្វើស្រែចម្ការយើង។

កៈ ធ្វើស្រែ ចុះគាត់ជាមនុស្សម្នាក់ដែលបែបណាដែរយាយ?

ខៈ ពីគាត់នៃកគ្មានរកអីទេ របៀបរបបគាត់អ្នកស្លូតបូតទេចៅ មិនមែនអ្នកកោងកាចប្រហើនអីទេ។ គាត់អ្នកបង់ត្រីដាក់មង់ដាក់សន្ទូចលប។

កៈ អូ! ចុះម្ដាយរបស់យាយ គាត់ធ្វើអីគេដែរយាយ?

ខៈ ធ្វើស្រែទាំងអស់គ្នាឯង។

កៈ ធ្វើស្រែទាំងអស់គ្នា។

ខៈ នោះឯង។ ចាស!

កៈ គាត់ជាមនុស្សបែបណាដែរយាយ?

ខៈ មើលយើង បើនិយាយពីប្រភេទអ្នករកស៊ី ដូចអ្នកមធ្យមចៅ ដូចអ្នកត្បាញរវៃ ដាំដុះដំណាំ យើងបង្ករបង្កើនផល ដាំដុះស៊ីចាំប្រចាំខ្លួនប្រចាំថ្ងៃចៅ។

កៈ ចុះគាត់កាចអត់យាយ?

ខៈ ទេ! បើប្ដីគាត់ផឹកស៊ីអីហ៊ានផឹកខិលខុលអីគាត់កំហើនដែលហ្នំ។

កៈ ហិហិ!

ខៈ អឺមាត់ធំមាត់តូចខ្លះដែរ មិនអត់សោះទេណាចៅណាំ។

កៈ ចាស! ចុះយាយមានចាំសាច់រឿងអីគេខ្លះដែលទាក់ទងនឹងពួកគាត់ដែរអត់យាយ?

ខៈ ទេចៅ យាយកាលនោះដូចល្ងង់ដែលគ្មានចាប់អារម្មណ៍ធ្វើអីៗយ៉ាងម៉េចៗទេ។ គាត់ឈ្លោះប្ដីប្រពន្ធគាត់ ប្រកែចតិចតួចក៏រត់លេងបាត់ទៅ។

កៈ អូ!

ខ៖ អឺ!

ក៖ ពេលដែលគាត់ស្លាប់និងយាយអាយុប៉ុន្មានហើយយាយ?

ខ៖ យាយអាយុគ្រែលហើយចៅ ១៧-១៨ ហើយ។

ក៖ អូ!

ខ៖ អឺ!

ក៖ ចុះគាត់មានដែលធ្លាប់ប្រាប់យាយពីជីវិតគាត់កាលគាត់នៅក្មេងទេយាយ?

ខ៖ ប្រាប់ដែរ តែជីវិតគាត់អ្នកខ្វះខាតខំរកអុស កាប់អុស ដាំបន្លែ ស៊ីឈ្នួលជួលព័ទ្ធគេចៅ ស្ទូងស្រូវ ដកស្ទូងដក ច្រូតកាត់ឯងណាចៅ។

ក៖ ចាស!

ខ៖ នោះឯង។

ក៖ អឺយមានចាំឈ្មោះជីដូនជីតារបស់យាយអត់យាយ?

ខ៖ ចាំតាឈ្មោះយាយតា  អំពីឪពុកម្ដាយគាត់ហាំណាំ។

ក៖ ចាស!

ខ៖ ឈ្មោះតាកែវ យាយបី អឺ តានុច យាយញ៉ែម ឪពុកៗយាយហ្គំ ឪពុកយាយទឹម ឈ្មោះតានុច យាយញ៉ែម ឪពុកតាប៉ាតមោះ តាកែវ យាយបី ប៉ុនមិនដឹងអាយុប៉ុន្មានទេចៅ ចាំតាឈ្មោះកើតអត់ទាន់គាត់ដែរ។

ក៖ ចាំត្រកូលគាត់អត់យាយ?

ខ៖ អត់ចាំទេចៅ។

ក៖ ចាស! ចុះយាយមានដែលឃើញឬក៏ជួបមុខពួកគាត់ទេយាយ?

ខ៖ មិនដែលទេចៅ កើតមកឮតែឈ្មោះ មិនបានឃើញមុខនៃកជីតាទេបានតែជួបតែជួបងមុខឪពុក។

ក៖ អឺ! ក្រុមគញ្ញរួសារយាយរស់នៅភូមិទឹកវិលហ្នឹងរយៈពេលយូរប៉ុនណាដែរយាយ?

ខ៖ អឺ! យូរដែលហើយចៅមិនដឹងជាប៉ុន្មានទេ ទាល់នឹងស្លាប់ចុះឯង ទាល់ឥឡូវ ទាល់នឹងថា...

ក៖ និយាយទៅតាំងពីយាយកើត។

ខ៖ អឺ!

ក៖ ពីឪពុកម្ដាយរបស់យាយមកជីដូនជីតាយាយនៅ នៅហ្នឹងដែរឬក៏អត់ទេ?

ខ៖ អឺ អឹម នៅនឹងទឹកវិលហ្នឹងឯងចៅ បើជីដូនជីតាខាងប្ដីយាយគេនៅភូមិវាលព្រីង។

ក៖ ចាស!

ខ៖ អឺ! បើឪពុកគាត់ឈ្មោះនែក តាពុធ យាយស៊ុន ម្ដាយគាត់ឈ្មោះយាយស៊ុន ឪពុកគាត់ឈ្មោះតាពុធ ដល់ម្ដាយឪពុកគាត់ឈ្មោះតាតែ យាយបិក។

ក៖ ហ្នឹងជាំ។

ខ៖ ឪពុកតាឆេងហ្នឹងហាំ។

ក៖ ប្ដីរបស់យាយហ្អ៎?

ខ៖ អត់ទេប្ដី ឪពុកតាឆេង តាឆេងប្ដីយាយហាំណាំ។

ក៖ អូ! ប្ដីរបស់យាយ។

ខ៖ ហ្នឹងអឺប្ដីរបស់យាយ។

ក៖ ចឹងប្ដីរបស់យាយ។

ខ៖ តា តែ ឆេង។

ក៖ ចឹងប្ដីយាយ លោកតាតែ ឆេង។

ខ៖ អឺ! តាឆេងប្ដីយាយ។

ក៖ យាយ!

ខ៖ តាតែ យាយបិកនោះ ម្ដាយតាឆេងឪពុកតាឆេង។

ក៖ ចាស! ចុះយាយរៀបការនៅក្នុងឆ្នាំណាដែរយាយ?

ខ៖ អឺយ៉ាចៅដូចភ្លេចហើយ ប៉ុនការនៅឆ្នាំរោង។

ក៖ ឆ្នាំរោង!

ខ៖ ដឹងតាឆ្នាំរោង ប៉ុនមិនដឹងនែក គេឆ្នាំបារាំងនោះមិនដឹងឆ្នាំទីប៉ុន្មានអីណា។

កៈ មុនប៉ុលពតឬក្រោយប៉ុលពតយាយ?

ខៈ មុនចៅ។

កៈ មុនប៉ុលពតហ្អ៎?

ខៈ ហ្នឹងហើយមុន។

កៈ ចាស!

ខៈ យាយការអាយុ១៧។

កៈ អឺ! រៀបការហ្នឹងយាយស្គាល់តាដោយខ្លួនឯងឬក៏ឪពុកម្ដាយគាត់អ្នករៀបចំ?

ខៈ នែក ម្ដាយឪពុកអ្នកដាក់ទុកទេចៅ គ្មានក្បត់ប្រពៃណីទេ តាមម៉ែពុកគាត់ដាក់ទុកឱ្យកូនជ្រើសរើសក្រុមគ្រួឱ្យកូន។

កៈ ចាស! កាលហ្នឹងមានថ្លៃជំនូនទេយាយ?

ខៈ ចុះមួយជំនាន់នោះទេដូចអត់ទេដឹងចៅដូចភ្លេចភ្លាំងទៅហើយ។

កៈ ហិហិ!

ខៈ ទេដូចតា សមតាមិនដែលហ្ន៎។

កៈ ហ្នឹងហើយ ប្រហែលជាយាយភ្លេចមើលទៅ។

ខៈ អឺ យាយភ្លេច។

កៈ ចុះអឺយាយ យាយអត់ដែលស្គាល់លោកតាតទេតាំងពីមុនរៀបការ?

ខៈ អត់ទេ ស្គាល់តែឪពូកនោះឯង ជីតាឮតាឪពុកប្រាប់ថាចៅ នែកតាកូនឯងឈ្មោះនេះៗដឹង  តែប៉ុននោះឯង ប៉ុនដឹងតាឈ្មោះទេណា៎ ត្រង់រូបរាងគាត់មិនបានឃើញនែកច្បាស់នឹងភ្នែកទេ បានតែម៉ែពុកគាត់ប្រាប់។

កៈ ចុះអឺយាយជួបគាត់ដំបូងនៅពេលណា?

ខៈ ម៉េចចៅ?

កៈ ចឹងនិយាយថាយាយឃើញមុខគាត់ដំបូងគេបង្អស់នៅពេលណា?

ខ៖ នៅពេលប្រហែលជាអាយុ ៣ ៤ ៥ ឆ្នាំប៉ុននោះឯងទេ ហើយរៀងស្រពិចស្រពិលដែល មួយជំនាន់នោះនោត ដែរ។

ក៖ អូ ហ្នឹងហើយ  ចឹងតាំងពីហ្នឹង ពីហ្នឹងមកអត់ដែលជួបមុខគាត់សោះ។

ខ៖ អត់តាំងពីនោះម៉ោរហូតដល់ឥឡូវនេះឯង។

ក៖ ទាល់ដល់ ដល់ទៅគាត់ ដល់ទៅការអត់ស្គាល់។

ខ៖ ដល់ទៅការ ការមានតែម៉ែពុកទេ តាយាយអត់មានទេ។

ក៖ អូ ហ្នឹងហើយ អឺ យាយមានបងប្អូនឬសាច់ញាតិណាដែលនៅក្រៅប្រទេសអត់?

ខ៖ អត់មានទេចៅ។

ក៖ យាយមានចេះភាសាអីក្រៅពីភាសាខ្មែរទេ?

ខ៖ គ្មានទេ ចេះតែប៉ុននេះឯងចៅ។

ក៖ ហិហិ!

ខ៖ ចេះតើ ចេះតែភាសា ចេះតាហូបចេះតាស៊ីចាំច្បាស់មែនទែន ខ្មែរចេះតែស៊ីហើយនិងភាសាប៉ុននោះឯង។

ក៖ ហិហិ!

ខ៖ គ្មានចេះញាំ ចេះសោយអីៗនឹងគេទេ ចេះតែពាក្យស៊ី ពាក្យភាសាហ្នឹងឯង។

ក៖ យាយរៀនថ្នាក់ទីប៉ុន្មានដែរយាយ?

ខ៖ ថ្នាក់ទី៣។

ក៖ ទី៣ កាលហ្នឹងគេរាប់ពីលើមកវិញឬក៏ក្រោម?

ខ៖ អឺ គេរាប់ពីលើមកឯងចៅ ពីកុមារឋាន បាវច្ចណឋាន អតិកឋាន រៀនអតិកឋាន។

ក៖ ចឹងមានន័យថាយាយរៀនបានច្រើនដែរ។

ខ៖ បានច្រើនក្រែលរបស់គេសណំដែលណាចៅ កាលនោះមានចេះបារាំងប្រូសអីនឹងគេទេ បានតែមើលសំបុត្រខ្លួនឯងស្គាល់។

ក៖ ចុះយាយមានចាំសាលាដែលយាយរៀននៅណាអត់?

ខ៖  នៅរកាជូរ ចាំតើថៅ។

ក៖ សាលារការជូរ ឈ្មោះសាលានឹងឈ្មោះពេញឈ្មោះអីគេយាយ?

ខ៖ សាលាពីណាមួយទៀត?

ក៖ ចង់និយាយថា ឈ្មោះសាលាពេញ ឈ្មោះសាលាដែលយាយរៀនហ៎ា។

ខ៖ ឯងឈ្មោះដែលគេដាក់ ឈ្មោះសាលារកាជូរ ប៉ុនមិនដឹង គេហៅស្អីតទៀតអត់ដឹងដែរ

ក៖ អូ!

ខ៖ អឹ!

ក៖ អូខេ!

ខ៖ ដឹងតែនាំគ្នាទៅរៀន រៀនសាលារកាជូរ។

ក៖ ចុះបន្ទាប់ពីយាយរៀនហើយ យាយធ្វើអីគេវិញដែលយាយ?

ខ៖ អាបន្ទាប់ពីរៀនហើយ យាយធ្វើស្រែចម្ការចិញ្ចឹមខ្លួន កាប់អុស ដងទឹក ចិញ្ចឹមម្ដាយចិញ្ចឹមប្អូន។

ក៖ ចុះ...

ខ៖ ធ្វើស្រែចម្ការ

ក៖ យាយមានជំនាញអីគេខ្លះដែរយាយ?

ខ៖ មានជំនាញស្អីថៅ មានតាជំនាញខាងស្រែហ្នឹងឯង ស្ទូងដកជ្រូតកាត់ដាំដុះបន្លែបន្លុកនោះឯង សណ្ដែកនរនោង ត្រឡាច ល្ពៅ។

ក៖ ចាស!

ខ៖ ហើយចិញ្ចឹកជ្រូកប៉ុននោះឯង សម្រាប់ចិញ្ចឹមជីវិត។

ក៖ ចាស! អឹ...

ខ៖ ប្រចាំថ្ងៃ។

ក៖ ខ្ញុំអាចសុំសួរយាយត្រូសៗ អំពីអ្វីដែលយាយគិតថាលំបាកនៅក្នុងជីវិតយាយ តាំងពីតូចរហូតដល់ប៉ុននេះទេយាយ?

ខ៖ ទ្រាំលំបាកតាំងពី គ្រុនឈឺស្កាត់ទាំងអស់ មិនដឹងរកលុយកាក់អីទិញថ្នាំដង្កៅអី ទៅកាប់ឬសឈើឬសព្រៃផឹក ស្ងោរទៅ បានលុយក៏យាយទិញថ្នាំពេទ្យ ថ្នាំអីលេបទៅ ពេលអត់ទៅក៏ផឹកសំបកឈើឬសឈើឯងទៅ។

ក៖ មានអីគេផ្សេងទៀតទេ ដែលលំបាកនៅក្នុងជីវិតយាយ?

ខ៖ លំបាកនឹងរោគគា ឈឺស្កាត់។

ក៖ សព្វថ្ងៃយាយឈឺអីគេខ្លះដែរ។

ខ៖ មិនស្រួលក្នុងឆ្អឹងក្នុងឆ្អែង។

ក៖ ឈឺក្នុង...

ខ៖ ឈឺក្បាល ហេវអស់កម្លាំង វិលមុខ

ក៖ ចាស! ចុះពី ពីអាជំនាន់ប៉ុលពតយាយរស់នៅណាវិញដែលយាយ?

ខ៖ ពីប៉ុលពតគេអត់មានជម្លៀសជម្លិញទៅណាទេ នៅនឹងស្រុកភូមិដដែលឯង។

ក៖ ពេលនិងយាយធ្វើអីគេដែល?

ខ៖ កាលប៉ុលពតហ្នឹង គេឱ្យជញ្ជូនដី។

ក៖ ជញ្ជូនដី។

ខ៖ អឺ គេឱ្យជញ្ជូនដីហើយនិងធ្វើអង្ករ។

ក៖ ធ្វើអង្ករ!

ខ៖ អឺ!

ខ៖ កិនបុកជាន់ហ្នឹងឯង យើងពីដើមគ្មានម៉ាស៊ីនទេចៅ។

ក៖ អូ!

ខ៖ មានតាកិនត្បាល់បុរាណយើងពីដើមហារ និងឯង ជាន់ត្បាល់ ត្បាល់គៀ្បងយើងហ្នឹងឯង។

គ៖ ដឹងទាន់ស្រួបណា។

ខ៖ អត់ទាន់មានទេបង កាលនោះជំនាន់នោះហ៉ាណា៎ ធត់ទាន់មានទា។

ក៖ ចឹងគេ!

គ៖ អទ់ទាន់មានទេស្រូបនោះ?

ខ៖ ចាស!

ក៖ គេអត់មាន។

ខ៖ មានតាត្បាល់កិន កិនរួចអុំ ជាន់ប៉ុននោះឯង។

គ៖ អានោអឯងគេហៅស្រូប។

ខ៖ អឺ អានោះឯង។

គ៖ គេយកស្រូបនោះឯងទៅជាន់។

ខ៖ ចាស!

ក៖ គេអត់មានអីយាយទេ កាលពីពេលហ្នឹង?

ខ៖ ទេចៅ គេមានតែឱ្យយើងលុតដំហូបអំបិលប៉ុន្មាន១កំប៉ុង ប៉ុន្មានថ្ងៃ ហិហិ ប៉ុន្មានថ្ងៃគេដាក់ផែនការណ៍ហូប បបរ គេធ្វើបាបត្រង់ឱ្យយាយលុតដំម្ហូប បបរលាយដំឡូង លាយគល់ចេក មើមក្រូចមើមអីនោះឯង ត្រពាំង ព្រលិត ត្រកួន។

ក៖ អូខេ! ចុះយាយមាន មាន១កូនប៉ុន្មាននាក់ដែរយាយ?

ខ៖ យាយកូន៥នាក់។

ក៖ គាត់ឈ្មោះអីគេដែរ?

ខ៖ សុទ្ធតែស្រី១ទាំងអស់ ស្រីទាំង៥-៦ទាំងចែកព្រីងមួយទៅនៅ៥.

ក៖ ចាស! គាត់ឈ្មោះអីគេខ្លះដែរយាយ?

ខ៖ ទី១ឈ្មោះ ពុធសារ៉ាត់ ទី២ពុធសារ៉ុន ទី៣ពុធនៃក សុខលឹមទី៤ពុធផលឡេ ទី៥ពុធសម័យ។

ក៖ ពួកគាត់សព្វថ្ងៃនៅណាខ្លះដែរយាយ?

ខ៖ កូនហ្អ៎? កូនខ្លះរស់នៅ វាលព្រីងអឺឃុំឈើទាលភូមិវាលព្រីង នៃកដល់បងប្អូនបន្តបន្ទាប់ទី១រស់នៅនឹងអាចារ្យ លាក់។

ក៖ ចាស!

ខ៖ អឺ ទី៥ហ្អ៊ំ រស់នៅនឹងអាចារ្យលាក់ដែរ ទី៤នៅនឹងស្ទឹងត្រែង អឺនឹងពុធសារ៉ុន។

ក៖ អឺ យាយពីក្មេង យាយធ្លាប់ស្រម៉ៃចង់ធ្វើជាអីគេដែលយាយ?

ខ៖ ចៅអើយ និយាយពីចង់នេះ ចង់ធំ ប៉ុនយើងអត់ចំណេះ យើងអត់លុយ។

ក៖ ចង់ធ្វើជាអីគេយាយ?

ខ៖ ចង់រៀនកាត់រៀនដេរ រៀនអឺ រៀនដាំស្លរយើងឱ្យចេះធ្វើម្ហូប ឆ្ងាញ់ៗនឹងគេ។

ក៖ ហិហិ មានស្អីផ្សេងទៀតដែលយាយចង់ធ្វើ?

ខ៖ អត់ទេ ប៉ុននោះឯងចៅ។

ក៖ ចាស! អឺ ហ្នឹងហើយយាយដោយសារ ការពិតសំណួរក្នុងនេះវាជិតអស់ហើយ ប៉ុន្តែខ្ញុំចង់ដឹងតិចៗទាល់ទងអឺនឹងតាសាន្ត។

ខ៖ អឺ!

ក៖ ដោយសារខ្ញុំចៅគាត់ ហើយអត់សូវដឹងច្រើនអំពីគាត់។

ខ៖ អឺ!

ក៖ ចឹងអឺ យាយចាំលោកតាសាន្តគាត់កើតនៅក្នុងឆ្នាំណាទេយាយ?

ខ៖ អត់ដឹងដែរចៅ។

ក៖ គាត់...

ខ៖ ដឹងតែឆ្នាំគាត់ៗឆ្នាំមមី។

ក៖ ឆ្នាំមមី!

ខ៖ តែគាត់ស្លាប់ប្រហែលជា៥០ជាងហើយ។ ចាស!

ក៖ ចាស! គាត់ស្លាប់។

គ៖ ឆ្នាំមមី កើតឆ្នាំមមីឯង។

ខ៖ អឺ ឆ្នាំមមី ប៉ុនអត់ដឹង ដឹងតែ។

គ៖ រាប់ពីមមីមក យើងប៉ុន្មានដឹងហើយ។

ខ៖ កាលនោះបើ...

ក៖ គាត់...

ខ៖ បើមមិន៥០ក៏៦០អីដឹងចៅ មួយជំនាន់នោះ។

ក៖ ខ្ញុំគ្រាន់តែដឹង...

ខ៖ អឺ ៦៣-៦៤អីដឹងហាង។

គ៖ តាសាន្តក្រោយហ្អំ បើមមីមួយសារមុន១០០ជាងហើយ

ក៖ ខ្ញុំគ្រាន់តែដឹងគាត់...

ខ៖ បែប៦០ជាងហើយដឹងហ្អំ ៦០-៧០ហើយដឹងឯង យូរក្រែលដែលហើយ ស្លាប់យូរដែរហើយ។

ក៖ គាត់ស្លាប់នៅក្នុងឆ្នាំ១៩៩៥  ចឹងបើគិតមកដល់ឥឡូវ២០ជាងហើយ។

ខ៖ អឺ ប៉ុននោះឯងដឹងចៅ

ក៖ ចាស! ប្រហែលជាខ្ទង់៨០ ៨០ឆ្នាំជាង បើរាប់មកដល់ឥឡូវ។

ខ៖ អឺ!

ក៖ ប៉ុន្តែគាត់បងយាយប៉ុន្មានឆ្នាំ។

ខ៖ មើល មមី មមែ វក បងយាយ៣ឆ្នាំ។

ក៖ បងយាយ៣ឆ្នាំ ចឹងគាត់កើតនៅឆ្នាំ១៩៤២ ហ្នឹងហើយ បើបងយាយ៣ឆ្នាំ។

ខ៖ អត់ទេចៅ យាយអត់ចេះគិតទេ។

ក៖ និងអត់អីទេ គាត់ៗកាចទេយាយ?

ខ៖ កាចដែល

ក៖ ហិហិ

ខ៖ ជេរបងជេរប្អូន បើបងប្អូនធ្វើមិនធ្វើតាម គាត់រករឿងវ៉ាយជេរដែល ប៉ុនតាអោយថាផឹកស៊ីរករឿងបងប្អូនម៉ែឪអត់ទេ គ្រាន់ថាជេរ ជេរប្អូន អញមិនធ្វើហើយអោយអញជួយទៀត អញដើរលេង

ក៖ ហិហិ

ខ៖ ប៉ុននោះឯង

ក៖ ចុះយាយ ឪពុកម្ដាយយាយអ្នកធ្វើស្រែន់យាយ

ខ៖ អឺ

ក៖ ចុះ ម៉េចលោកតាសាន្តគាត់ធ្វើជាទាហ៊ាន ហើយសាកគាត់ដូចជារាងធំដែល

ខ៖ រាងអីរាងធំនិងឯងចៅ ម៉ាជំនាន់នោះ ក្នុងម៉ាស្រុសសណ្ដាន់ មានតាគាត់ឯងអ្នកបើកភរភាស់ ខាងសេចកិច្ចលុយកាក់នោះអីចៅ

ក៖ ចា

ខ៖ អឺ

ក៖ តាមដែលដឹងគាត់ដូចជាអ្នក

ខ៖ អឺ

ក៖ បើកលុយអោយ

ខ៖ អ្នកបើកអោយប្រជាពលរដ្ឋ រាស្ត្រ

ក៖ ទាហ៊ានម៉ាខេត្តកំពង់ធំ

ខ៖ ទាហ៊ានមួយខេត្តហ្នឹងឯង។

ក៖ បាទ! គាត់ធ្វើដូចជា ឪពុកម្ដាយជាកសិករ។

ខ៖ ហ្នឹងឯង។

ក៖ ប៉ុនគាត់អាចធ្វើជា...

ខ៖ អាចជាមន្ត្រីរាជការបាន។

ក៖ មន្ត្រីរាជការបាន

ខ៖ ព្រោះអីម្ដាយតស៊ូ លក់គោលក់ក្របី ស៊ីឈមូលជួលពាត់ទៅ បានលុយឱ្យកូនខំរៀ កុំឱ្យល្ងង់ដូចម៉ែដូចឪ ហើយកុំឱ្យល្ងង់តបងតប្អូនទៀត។ គាត់ខំរៀៗថាកូនជាកូនប្រុសមួយមកខំរៀន លាពីដងចបដងនង្គ័ល កុំឱ្យស្គាល់ដំចបដូចបងប្អូនដូចម៉ែដូចឪយើងពីមុនមក  ឱ្យកើតទាន់សង្គមគេដឹកនាំ ត្រូវការអ្នកចេះ។

កៈ ចាស! ចុះគាត់ជួយបងប្អូនអត់យាយតាសាន្ត?

ខៈ មិនសូវគិតទេ។ គាត់ប្រុសមួយជំនាន់នោះគាត់ត្រូវការសប្បាយច្រើន មិនសូវគិតបងគិតប្អូនទេ ដល់គិតបងប្អូន ដល់ពេលបុណ្យហ្នឹងឯងទៅបានគាត់ថាហ៎ា អាដែងជួបជុំបងប្អូនយើងផឹកយើងស៊ីតិចតួចណា។ កាលនោះយើងនៅលុយតិចដែលចៅ។

កៈ ចឹងគាត់អត់ដែលសូវជូនលុយជូនអីឱ្យ។

ខៈ អឺ មិនសូវទេចៅ គាត់គិតតែមកសប្បាយគាត់ស្រីញីគាត់។

កៈ ហិហិ

ខៈ មួយជំនាន់នោះ។

កៈ តែឮស្រីដែរហ្នឹងណា៎។

ខៈ អឺ ស្រីហើយស្រី ចុះដន្លងគាត់ស្រីដែរ ហិហិឮ។

កៈ ហិហិ កុងសេងហ្អ៎។

ខៈ ហិហិ អឺ កុងសេង។

កៈ ហិហិ!

ខៈ កុងសេង កុងសាន្ត កុងសុងហ្អ៎សុទ្ធតែដៃជើងគាត់ហើយ សេរីគាត់ហើយ។

កៈ ហិហិ ហ្នឹងហើយ ចឹងអឺសំណួរមួយទៀត បើសិនជាយាយមានអីគេចង់ផ្តាំផ្ញើទៅកាន់កូនចៅជំនាន់ក្រោយ តើយាយចង់និយាយអីគេទៅកាន់ទៅកាន់ពួកគាត់ដែរ?

ខៈ អីហ្នឹងខ្លួនយាយសព្វថ្ងៃហាក់? ចង់ផ្តាំផ្ញើរឱ្យកូនចៅក្រោយៗខំរៀនខំសូត្រឱ្យចេះឱ្យដឹង ទាន់សង្គមគេត្រូវការអ្នកចេះ។

កៈ ចាស!

ខៈ កុំឱ្យឆោតល្ងង់ដូចមួយជំនាន់យាយ មួយជំនាន់យាយពីតើ ម៉ែអត់រៀនបានច្រើនទេ ខ្លាចលោរៀនទៅ...

កៈ មនុស្ស!

ខៈ មានទាក់ទងសង្សារអីណាអីណីរត់ចោលម៉ែ រត់តាមប្តីបាត់ រត់តាមប្រុសបាត់រត់ចោលម៉ែ។

កៈ ហិហិ

ខ៖ បានមកដល់ជំនាន់នេះ យាយផ្ដាំផ្ញើរឱ្យកូនចៅទាំងអស់គ្នា ខំរៀនខំសូត្រឱ្យចេះឱ្យដឹងពីជីវភាពយើងខ្វះខាត ចំណេះចេះដឹង ដឹងទៅតាមសង្គមគេដឹកនាំ។

ក៖ ហ្នឹងហើយ។

ខ៖ ធ្វើយ៉ាងម៉េចៗឱ្យចៅក្រោយៗនេះដោយលូតលាស់តទៅទៀតទៅមុខទៀត។

ក៖ ចាស! ចឹងមានអីផ្សេងទៀតអត់យាយ?

ខ៖ ទេ! បើតាមក្នុងចិត្តអស់ប៉ុននោះឯងចៅ។

ក៖ ហិហិ!

ខ៖ យាយចប់ហើយ។

ក៖ ហ្នឹងអត់អីចឹង ចុងក្រោយអរគុណយាយដែលអនុញ្ញាតិដើម្បីខ្ញុំអាចសម្ភាសយាយ ហើយអឺបន្ទាប់ពីហ្នឹងខ្ញុំសុំអនុញ្ញាតិដើម្បីថតរូបយាយទុកយើងនិងអឺ មួយទៀតខ្ញុំសុំអនុញ្ញាតិយាយដើម្បីអាចផុសអាសារសម្លេងហ្នឹងចូលទៅក្នុងអឺវេបសាយរបស់សាកលវិទ្យាល័យព្រឹកហាំយ៉ងបានទេយាយ?

ខ៖ ដឹងអីចៅ ដឹងអីយាយ អូស ចៅឯងធ្វើម៉េចយ៉ាងម៉េចស្រេចតែចៅទេ អត់ដឹងអីទេយាយ បានតែថាប្រាប់ចៅតែប៉ុននេះឯង។

ក៖ ហ្នឹង ដូចជានៅពេលដែលពួកយើងធ្វើមួយហ្នឹង យើងនឹងផុសវាទៅក្នុងវេបសាយរបស់សាកលវិទ្យាល័យព្រឹកហាំយ៉ង សាកលវិទ្យាល័យហ្នឹងនៅសហរដ្ឋអាមេរិច ហើយដើម្បីអាចដូចជាកូនចៅជំនាន់ក្រោយរបស់យើងគាត់អាចរៀនអំពីជីវប្រវត្តិយាយឬក៏ ដូនតាមុនៗរបស់យើង។

ខ៖ ដូចពីដើមៗមកហ៎។

ក៖ ដើម្បីយើងអាចដឹង ចាស! ចឹងលុំត្រាតែយាយអនុញ្ញាតិដើម្បីយើងអាចផុសវាបាន បានយើងហ៊ានផុសមួយហ្នឹង ព្រោះមួយហ្នឹងគឺជាសារសម្លេងរបស់យាយ ចឹងត្រូវការ។

ខ៖ ជាការពិត

ក៖ អនុញ្ញាត ចាស ចឹងយាយអនុញ្ញាតិដើម្បីអោយខ្ញុំអាចផុសវាបានទេយាយ អនុញ្ញាតឬក៏មិនអនុញ្ញត។ បើសិនជាយាយគិតថាអត់អី អនុញ្ញតខ្ញុំនិងផុស បើសិនជាយាយថាអត់ទេ ខ្ញុំក៏អត់ហ៊ានផុសដែល

ខ៖ ចា បើនិយាយតាមដែលយាយល្ងង់យាយមិនចេះគិត ដែលថានោអស្រេចនិងចៅទេ ចៅផុសយ៉ាងម៉េចក៏តាមយោបល់ចៅនែកចៅយល់

ក៖ ហិហិ

ខ៖ ហ្នឹងខ្លួនចៅណាចៅ

ក៖ ចាសហ្នឹងហើយ។ ចឹងខ្ញុំសុំអនុញ្ញាតយាយ ដោយសារយាយឱ្យខ្ញុំសម្រេច ចឹងខ្ញុំសុំអនុញ្ញាតដើម្បីផុសមួយហ្នឹងទៅលើវេបសាយ ចឹងដើម្បីថ្ងៃក្រោយខ្ញុំ។

ខ៖ ក្រែងលោបានដឹង

ក៖ ចាស! ថ្ងៃក្រោយខ្ញុំឬក៏អ្នកក្រោយ គាត់អាចស្រាវជ្រាវពីយាយបានម្ដងទៀត។

ខ៖ ចាស!

ក៖ ដោយសារ បើសិនជាខ្ញុំទុកតែក្នុងទូរសព្ទ ពេលខ្លះទូរសព្ទយើងខូចឬក៏បាត់ ចឹងខ្ញុំអត់ដឹងថាទៅយកពីណាទេ។

ខ៖ អឺ ដឹងទៅរកអីណាទៀតទេ។

ក៖ បា បើខ្ញុំផុសនៅក្នុងហ្នឹង ខ្ញុំអាចរកបានវិញនៅថ្ងៃក្រោយ ចឹងសម្រាប់ថ្ងៃហ្នឹង។

ខ៖ ហើយពេលក្រោយបានជួបយាយយើងទៀត។

ក៖ ចាស! សម្រាប់ថ្ងៃហ្នឹង ខ្ញុំមានតែប៉ុណ្ណឹង សម្រាប់ការសម្ភាសមួយហ្នឹង។ ចឹងអរគុណយាយដែលអនុញ្ញាត្តិ។

ខ៖ អឺចៅ

ក៖ ហើយខ្ញុំសុំ

ខ៖ សុំឱ្យចៅអាយុវែង

ក៖ ចាស! ហើយខ្ញុំសុំអឺបិទ បិទអានេះ។

ខ៖ ឱ្យចៅឈ្លាសវៃ ទៅតាណាក៏ឱ្យចេះដឹងណាចៅណា។

ក៖ ចាសៗយាយ!

ខ៖ ហ្នឹងឯង។

ក៖ ចៅអរគុណច្រើនយាយ៕